( ៣២ )

# ប្រកាសស្តីពី

# ភាគពួកកិច្ចសារពើពន្ធចំពោះសហគ្រាស

# ដែលអនុវត្តពហុគម្រោង

លេខៈ ១១២៧ សហវ.ប្រក

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៦៥ សហវ.បក

នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ
មកដល់ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២
លេខ ...
ម៉ោង ...

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ...
ថ្ងៃទី ...
បញ្ជូន ...

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងកាតព្វកិច្ចសារពើពន្ធ
## ចំពោះសហគ្រាសដែលអនុវត្តគម្រោង

---

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់ក្នុងការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

## ប្រការ ៤.- ការចុះបញ្ជី និងការផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ

ដូចមានចែងក្នុងមាត្រា៣ ថ្មី និងមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា៥.៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលដៅពន្ធដារ÷

១- សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.ត ឬអនុវត្តគម្រោង គ.ល.ត ផង និងមិនមែន គ.ល.ត ផង ឬពហុគម្រោងមិនមែន គ.ល.ត ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងត្រូវបានផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធដោយឡែកៗពីគ្នា។

២- គម្រោង គ.ល.ត នីមួយៗ ឬគម្រោងមិនមែន គ.ល.ត នីមួយៗ ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធមួយដោយឡែកៗពីគ្នា។

## ប្រការ ៥.- ភាតព្វកិច្ចសារពើពន្ធ និងកិច្ចបញ្ជិកាគណនេយ្យរបស់សហគ្រាស

សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.ត ឬអនុវត្តគម្រោង គ.ល.ត ផង និងមិនមែន គ.ល.ត ផង ឬពហុគម្រោងមិនមែន គ.ល.ត ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការ៤ ខាងលើ ត្រូវ÷

១- ស្នើសុំចុះបញ្ជី និងប្រកាសបង់ពន្ធប៉ាតង់សម្រាប់គម្រោងនីមួយៗនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយគម្រោងនីមួយៗធ្វើសកម្មភាពសេដ្ឋកិច្ច។

២- ញែកដាច់ពីគ្នាដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗសម្រាប់បម្រើឱ្យគម្រោងនីមួយៗ។

៣- កាន់កាប់និងកត់ត្រាបញ្ជិកាគណនេយ្យ និងត្រូវបែងចែកឱ្យបានត្រឹមត្រូវនូវចំណូល និងចំណាយ ដែលកើតឡើងដោយឡែកៗពីគ្នាសម្រាប់គម្រោងនីមួយៗ។

៤- ចំពោះចំណូល និងចំណាយដែលមិនអាចបែងចែកដាច់ដោយឡែកពីគ្នាតាមគម្រោងនីមួយៗ សហគ្រាសត្រូវធ្វើការបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោលធៀបនឹងចំណាយ។ ក្នុងករណីទាក់ទិននឹងគម្រោងដែលមិនទាន់មានផលរបរ សហគ្រាសត្រូវបែងចែកតាមសមាមាត្រទំហំនៃការប្រើប្រាស់ទ្រព្យសកម្ម ឬទំហំនៃចំណាយទាំងនោះ។ ចំណាយសមាមាត្រទាំងនោះ រួមមាន ចំណាយរដ្ឋបាលរួម ចំណាយជួលការិយាល័យរួម ប្រាក់បៀវត្សអ្នកគ្រប់គ្រង ឬបុគ្គលិកទទួលខុសត្រូវរួម និងចំណាយផ្សេងៗទៀតសម្រាប់បំរើសកម្មភាពច្រើនជាងមួយគម្រោង។

៥- កាន់កាប់ កត់ត្រា និងរក្សាបញ្ជីស្តុកទំនិញ ផលិតផលសម្រេច ផលិតផលពាក់កណ្តាលសម្រេច វត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗគ្នាសម្រាប់គម្រោងនីមួយៗដាច់ដោយឡែកពីគ្នា។

៦- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលមិនអាចធ្វើការបែងចែកបាន ហើយត្រូវបានប្រើប្រាស់លាយឡំគ្នា សហគ្រាសត្រូវកត់ត្រាតាមដាន និងធ្វើរំលស់នៃទ្រព្យទាំងនោះនៅក្នុងគម្រោងដែលទ្រព្យសកម្មនោះត្រូវបានកត់ត្រាដំបូង ហើយត្រូវធ្វើការបែងចែកចំណាយទាយជូតាន

ឆ្នាំ២០១៦ រហូតដល់ប្រកាសនេះចូលជាធរមាន សហគ្រាសត្រូវញែកឥណទានយោងទៅលើទាំងនោះ តាមគម្រោងនីមួយៗ និងត្រូវធ្វើការកែតម្រូវលិខិតប្រកាសអាករលើតម្លៃបន្ថែមប្រចាំខែនីមួយៗ។

## ប្រការ ៧.- ការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ

សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ តាមគម្រោងនីមួយៗដាច់ដោយឡែកពីគ្នា ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

## ប្រការ ៨.- ពហុគម្រោងមិនមែន គ.ល.គ ជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា

ចំពោះសហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោងមិនមែន គ.ល.គ ត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា ទោះបីមានសកម្មភាពអាជីកម្មច្រើនក៏ដោយ ត្រូវបំពេញកាតព្វកិច្ចសារពើពន្ធបញ្ចូលគ្នាតែមួយដូចជា ការចុះបញ្ជីនិងលេខអត្តសញ្ញាណកម្មសារពើពន្ធ ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យ និងដាក់លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ព្រមទាំងកាតព្វកិច្ចសារពើពន្ធដទៃទៀត តាមបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

## ប្រការ ៩.- ការអនុវត្តប្រកាស

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៦

ពន្លឺ មុនីឡៃ

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ